# ជំនួយស្មារតី

## ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំកម្ពុជា-កូរ៉េ ឆ្នាំ២០២៤

## សម្រាប់កិច្ចប្រជុំ SOMTC នៅទីក្រុងវៀងចន្ទន៍

ចាប់ពីថ្ងៃទី២៦-២៨ ខែមិថុនា ឆ្នាំ២០២៤

## I. អនុស្សរណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងផ្សេងៗ

- **អនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងគ្រឿងញៀន និងអង្គការឧក្រិដ្ឋកម្មដោយមានការចាត់តាំង** (មិនកំណត់រយៈពេលនៃសុពលភាព) រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៃព្រះរាជាណាចក្រកម្ពុជា និងការិយាល័យអគ្គរដ្ឋអាជ្ញា នៃសាធារណរដ្ឋកូរ៉េ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅទីក្រុងសេអ៊ូល (ភាគីកម្ពុជាតំណាងដោយ **សម្តេចក្រឡាហោម ស ខេង**)។
- **អនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** រវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងទីភ្នាក់ងារនគរបាលជាតិកូរ៉េ (មិនកំណត់រយៈពេលនៃសុពលភាព) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ នៅទីក្រុងសេអ៊ូល (ភាគីកម្ពុជាតំណាងដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន** អគ្គស្នងការនគរបាលជាតិ)។
- **អនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យអភិបាលកិច្ចសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ** រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងមហាផ្ទៃ និងសុវត្ថិភាពកូរ៉េ (សុពលភាពរយៈពេល ០២ឆ្នាំ និងអាចបន្តដោយស្វ័យប្រវត្តិ បើគ្មានការស្នើសុំបញ្ចប់) ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ (ភាគីកម្ពុជាតំណាងដោយ **ឯកឧត្តម សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ)។
- **អនុស្សរណៈនៃការយោគយល់ ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន** រវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងទីភ្នាក់ងារចារកម្មជាតិ នៃសាធារណរដ្ឋកូរ៉េ (មានរយៈពេល ០៣ឆ្នាំ) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ទីក្រុងសេអ៊ូល (ភាគីកម្ពុជាតំណាងដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិ)។

## II. អំពីជំនួបទ្វេភាគីកន្លងមកនៅក្នុងកិច្ចប្រជុំ SOMTC កន្លងមក

១. លទ្ធផលជំនួបជាមួយតំណាងក្រសួងយុត្តិធម៌ នៃសាធារណរដ្ឋកូរ៉េ នៅក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី២៣ ភាគីកូរ៉េបានស្នើសុំកិច្ចសហការស៊ើបអង្កេតពលរដ្ឋកូរ៉េ ០១រូប ឈ្មោះ Seon Jong Goo (SUN Veasna) ដែលត្រូវតុលាការកូរ៉េ ផ្តន្ទាទោសករណីបទល្មើសសេដ្ឋកិច្ចអន្តរជាតិ ដែលជនសង្ស័យនេះមានសញ្ជាត់ខ្មែរ និងកំពុងលាក់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- ➢ *ភាគីកម្ពុជាឆ្លើយតប៖ ករណីនេះក្រសួងមហាផ្ទៃ បានទទួលសំណើរបស់ភាគីកូរ៉េហើយ តែករណីនេះស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌។ ទោះបីយ៉ាងណា ក្រសួងមហាផ្ទៃត្រៀមផ្តល់កិច្ចសហការក្នុងកិច្ចការពាក់ព័ន្ធ។*

– ករណីនេះដែរស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា បានស្នើសុំក្រសួងយុត្តិធម៌កម្ពុជា ក្នុងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់លើវិស័យព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងឈ្មោះ Seon Jong Goo ឬ SUN Veasna ដែលត្រូវបានអាជ្ញាធរកូរ៉េចោទប្រកាន់លើបទល្មើសដែលប្រព្រឹត្តនៅកូរ៉េ។

- ➢ បុគ្គលនេះមានទោសនៅប្រទេសកូរ៉េ ចំនួន ០៥ឆ្នាំ ពាក់ព័ន្ធនឹងការគេចពន្ធ ប្រតិបត្តិការប្តូរប្រាក់ខុសច្បាប់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ប៉ុន្តែបានរត់គេចខ្លួន។
- ➢ លោក Seon Jong Goo កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៤៧ បានទទួលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ (រ.ក្រ ០៨១៩/១៣៦៥) លិខិតឆ្លងដែន N០១៧៧៣៤៩១ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ០១១៣៥៨៦៩០ ឈ្មោះ SUN Veasna ដោយមិនឆ្លងតាមរយៈក្រសួងមហាផ្ទៃ។
- ➢ បុគ្គលខាងលើបានធ្វើដំណើរចូលមកកម្ពុជាលើកដំបូង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩តាមប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជើងហោះហើរ SQ ១៥៨ និងដាក់អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៣០-៣២ ផ្លូវជាតិលេខ៦ ភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- ➢ ក្រសួងមហាផ្ទៃ បានស្នើភាគីកូរ៉េ ដាក់សំណើករណីពាក់ព័ន្ធឈ្មោះ SUN Veasna ទៅក្រសួងយុត្តិធម៌ ដើម្បីចាត់ចែងតាមនិតិវិធី។

២. ភាគីកូរ៉េ បានស្នើសុំពន្លឿននីតិវិធិក្នុងការធ្វើកោសល្យវិច័យលើសពស្ត្រីជនជាតិកូរ៉េ ០១រូបឈ្មោះ Byin A. Yeong ដែលបានស្លាប់ក្នុងក្លិនិករបស់ជនជាតិចិនមួយកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- ➢ *ភាគីកម្ពុជាឆ្លើយតប៖ ករណីនេះក្រសួងមហាផ្ទៃ កំពុងតែបន្តនីតិវិធីស៊ើបអង្កេត និងជំរុញនីតិវិធីដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ និងក្រុមគ្រួសារ។*

## III. កិច្ចសហប្រតិបត្តិការសន្តិសុខ និងស្ថានភាពពលរដ្ឋកូរ៉េ

### ១-កិច្ចសហការបង្ក្រាបបទល្មើស និងស្រាវជ្រាវ (ត្រីមាសទី០១ ឆ្នាំ២០២៤)

- តាមរយៈនគរបាលអន្តរជាតិ បានទទួលសំណើពី NCB Seoul និងតាមរយៈស្ថានទូតចំនួន ១៣ករណី។
  - ក្រសួងមហាផ្ទៃបានឆ្លើយតប ០៣ករណី (កំណត់ត្រាអន្តោប្រវេសន៍ ព័ត៌មានគណនីធនាគារ និងកំណត់ទីតាំងជនសង្ស័យ)
  - កំពុងបន្តស្រាវជ្រាវ ១០ករណី។

- ទទួលសំណើសុំអន្តរាគមន៍ស្វែងរកពលរដ្ឋកូរ៉េចំនួន ១០នាក់។
  - ស្រាវជ្រាវឃើញ ០១នាក់
  - រកពុំឃើញក្នុងទីតាំង ០៧នាក់
  - កំពុងបន្តស្រាវជ្រាវ ០២នាក់។

**២-ពលរដ្ឋកូរ៉េកំពុងជាប់ឃុំក្នុងពន្ធនាគារនៅកម្ពុជា**

- គិតត្រឹមថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ មានជនជាតិកូរ៉េចំនួន ២០រូប កំពុងជាប់ឃុំនៅក្នុងប្រទេសកម្ពុជា (ជនត្រូវចោទ ១៥រូប និងពិរុទ្ធជន ០៥រូប)។

**៣- ស្ថានភាពពលរដ្ឋកូរ៉េ (ត្រីមាសទី០១ ឆ្នាំ២០២៤)**

- ប្រព្រឹត្តបទល្មើស ១៤នាក់ (ហិង្សាដោយចេតនា ០៥នាក់ ស្នាក់នៅខុសច្បាប់ ០៦នាក់ និងជួញដូរសាជាតុញៀន ០៣នាក់)
- ស្លាប់ ០៧នាក់ (គាំងបេះដូង ០៤នាក់ អត្តឃាត ០២នាក់ និងលង់ទឹក ០១នាក់)
- រងគ្រោះ ០២នាក់ (ចោរលួចសម្ភារៈ និងហិង្សា)។

**៤-ករណីស្រាវជ្រាវជនជាតិកូរ៉េខាងជើង ឈ្មោះ KIM TONG UK**

- ស្ថានទូតសាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យកូរ៉េ បានស្នើសុំមកក្រសួងមហាផ្ទៃស្រាវជ្រាវរកជនជាតិកូរ៉េខាងជើង ឈ្មោះ KIM TONG UK តាមរយៈកំណត់ទូតលេខ ០២៧/០២៤ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ និងកំណត់ទូតលេខ៣៣/០២៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤។
- យោងតាមការស្រាវជ្រាវបានបង្ហាញថា ជនជាតិកូរ៉េខាងជើងឈ្មោះ KIM TONG UK បានដើរចូលស្ថានទូតកូរ៉េខាងត្បូង នៅកោះពេជ្រ នៅម៉ោង ០៨:៥៥នាទីព្រឹក ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤។
- ករណីនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មិនទាន់បញ្ជាក់ជាផ្លូវការយ៉ាងណានៅឡើយទេ។

៥-ករណីជនសង្ស័យជនជាតិកូរ៉េខាងត្បូងឈ្មោះ Lee Yongjin

- ជនសង្ស័យជនជាតិកូរ៉េខាងត្បូងឈ្មោះ Lee Yongjin ភេទប្រុស កើតថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៧ ប្រើប្រាស់លិខិតឆ្លងដែន M៤៤៩J៤៦០១ ដែលស្ថិតក្នុងបញ្ជីនិវទន៍ក្រហមពីបទឃាតកម្មនៅក្នុងប្រទេសថៃ នឹងត្រូវបានចាប់ខ្លួននៅប្រទេសកម្ពុជា កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៤ ។
  + កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤ ស្ថានទូតកូរ៉េប្រចាំកម្ពុជា បានផ្ញើកំណត់ទូតមកក្រសួងមហាផ្ទៃ ដើម្បីស្នើសុំឱ្យប្រគល់ជនសង្ស័យខាងលើមកទីភ្នាក់ងារនគរបាលជាតិកូរ៉េ (KNPA) ដើម្បីនាំខ្លួនត្រឡប់ទៅប្រទេសកូរ៉េវិញ។

+ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌កូរ៉េ បានផ្ញើកំណត់ទូតមកក្រសួងមហាផ្ទៃ ដើម្បីស្នើសុំឱ្យបញ្ជូនជនសង្ស័យខាងលើត្រឡប់ទៅប្រទេសកូរ៉េវិញ ដោយយោងតាមកិច្ចព្រមព្រៀងបត្យាប័នរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលកូរ៉េ។

- ករណីនេះអគ្គស្នងការដ្ឋាននគរបាលជាតិកំពុងបន្តនីតិវិធី

**៦-ដំណើរចូល-ចេញ របស់ពលរដ្ឋកូរ៉េ (រយៈពេល ០៥ខែ ក្នុងឆ្នាំ២០២៤)**

- ជនជាតិកូរ៉េបានធ្វើដំណើរចូលសរុបចំនួន ៨៩,២៤០នាក់។
- ជនជាតិកូរ៉េបានធ្វើដំណើរចេញសរុបចំនួន ៩១,០៤៩នាក់។

**៧-ពលរដ្ឋកូរ៉េបណ្តេញចេញពីកម្ពុជា (គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤)**

- បានបណ្តេញចេញនូវជនជាតិកូរ៉េខាងត្បូង ដែលបានប្រព្រឹត្តខុសច្បាប់អន្តោប្រវេសន៍ចំនួន ១៩នាក់ និងកំពុងស្នាក់នៅត្រៀមបណ្តេញចេញចំនួន ០៨នាក់។

**៨-ទិន្នន័យផ្តល់ទិដ្ឋាការ (រយៈពេល ០៥ខែ ក្នុងឆ្នាំ២០២៤)**

- បានផ្តល់ទិដ្ឋាការចូលចំនួន ៥, ៨៦៩នាក់
- បានបន្តទិដ្ឋាការស្នាក់នៅចំនួន ៨,២៩៥នាក់
- បានផ្តល់ទិដ្ឋាការចេញចំនួន ២៤១នាក់។

## IV. ការផ្លាស់ប្តូរទស្សនកិច្ច និងការវិនិយោគ

❖ **កិច្ចប្រជុំ**

- នាយនគរបាលជាតិជាន់ខ្ពស់ចំនួន ០២រូប ចូលរួមប្រជុំពិនិត្យពិចារណាក្នុងការចុះហត្ថលេខាលើក្រមប្រតិបត្តិ នៃក្រុមកិច្ចសហប្រតិបត្តិការពហុភាគី ជាមួយសមត្ថកិច្ចប្រឆាំងបទល្មើសគ្រឿងញៀនក្នុងតំបន់អាស៊ី នៅសាធារណរដ្ឋកូរ៉េ ចាប់ពីថ្ងៃទី២៦-២៩ ខែកុម្ភៈ ឆ្នាំ២០២៤។ *(គ្រោងចុះហត្ថលេខានៅឆ្នាំ២០២៥)*

❖ **ទស្សនកិច្ចការងារ**

- គណៈប្រតិភូកូរ៉េ ដឹកនាំដោយលោក SANGKTOO IM រដ្ឋអាជ្ញា និងជាអនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃមហាអយ្យការតុលាការកំពូល ជួបពិភាក្សាការងារជាមួយគណៈប្រតិភូចំនួន ០៥រូប នៃនាយកដ្ឋានចារកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤)។
- គណៈប្រតិភូកូរ៉េ ដឹកនាំដោយលោក SHIN YONGHWA អគ្គនាយករង KOICA CAMBODIA ជួបពិភាក្សាការងារជាមួយគណៈប្រតិភូចំនួន ០៤រូប នៃនាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤)។

❖ **ការងារវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** (CDC)

- គិតត្រឹមត្រីមាសទី០១ ឆ្នាំ២០២៤ អ្នកវិនិយោគកូរ៉េខាងត្បូងបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) មានចំនួន ២២៥ក្រុមហ៊ុន ដែលទុនវិនិយោគសរុបចំនួន ៤,២៨៦,៦១៧,៦៥១ ដុល្លារ ក្នុងនោះ៖
  - វិនិយោគវិស័យរោងចក្រ សហគ្រាសចំនួន ១៩២ក្រុមហ៊ុន
  - វិនិយោគវិស័យកសិកម្ម ១៦ក្រុមហ៊ុន
  - វិនិយោគវិស័យទេសចរណ៍ ៦ក្រុមហ៊ុន
  - វិនិយោគវិស័យហេដ្ឋារចនាសម្ព័ន្ធ ១១ក្រុមហ៊ុន។

## V. ការចងសម្ព័ន្ធមេត្រីភាព

| ល.រ | រាជធានី-ខេត្ត (កម្ពុជា) | រដ្ឋធានី-ខេត្ត (កូរ៉េ) | ផ្សេងៗ |
|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ក្រុងអ៊ិនឆន | |
| | | ក្រុងប៊ូសាន | |
| ២ | ខេត្តសៀមរាប | ខេត្តជុងចុងណាំដូ | |
| | | ក្រុងស៊ូវ៉ុន | |
| | | ខេត្តកាងវ៉ុន | |
| ៣ | ខេត្តព្រះសីហនុ | ក្រុងឆាងវ៉ុន | |
| | | ក្រុងគូរី | |
| ៤ | ខេត្តបាត់ដំបង | ក្រុងស៊ូវ៉ុន | |
| ៥ | ខេត្តកំពង់ចាម | ក្រុងណាមយ៉ាងជូ | |
| ៦ | ខេត្តកំពត | ខេត្តយុងគី | |
| ៧ | ខេត្តកំពង់ស្ពឺ | ខេត្ត Gollanam-do | |
| ៨ | ខេត្តត្បូងឃ្មុំ | Lions Club International District 355-B3 | |

## VI. ស្ថានភាពទូទៅនៅប្រទេសកម្ពុជា

❖ **ស្ថានភាពជនជាប់ឃុំនៅកម្ពុជា**

- ជនជាប់ឃុំគិតត្រឹមថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៤ សរុបចំនួន ៤៦.៤១០នាក់ (ស្រី២.៨១៨នាក់)។
  - ជនត្រូវចោទ ៩.៩៣៧នាក់ (ស្ត្រី ៧៣០នាក់)
  - ជនជាប់ចោទ ៥.២៦៦នាក់ (ស្ត្រី ៣៤០នាក់)
  - ពិរុទ្ធជន ១៩.០២១ (ស្ត្រី ១.០៦៧នាក់)
  - ទណ្ឌិត ១២.១៨៦នាក់ (ស្ត្រី ៦៨១នាក់)

- ជនជាប់ឃុំជាជនជាតិបរទេស សរុបចំនួន ២.៥១៦នាក់ (ស្ត្រី ២៨២នាក់) ដែលមាន ៤៧ជនជាតិ។
  - អនីតិជនចំនួន ២.៦៩៧ (ស្ត្រី ៩២នាក់) ស្ត្រីមានផ្ទៃពោះចំនួន ៤៨នាក់ កូនតាមម្តាយចំនួន ១០៩នាក់
- ពាក់ព័ន្ធបទល្មើសគ្រឿងញៀនចំនួន ២២.២២៤នាក់ (ស្ត្រី ១.៧៧៣នាក់) ស្មើនឹង ៤៨.៣៨%។

❖ **ស្ថានភាពបទល្មើសព្រហ្មទណ្ឌនៅកម្ពុជា**

- គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ លទ្ធផលបទល្មើសព្រហ្មទណ្ឌ សរុបចំនួន ១៧៩លើក កើនឡើង ៣១លើក ប្រមាណជា ២១% បើធៀបទៅនឹង ត្រីមាសទី១ ឆ្នាំ២០២៣។
  - លួចមានស្ថានទំងន់ កើនឡើងចំនួន ២ករណី ស្មើនឹង ៥%
  - ឃាតកម្ម កើនឡើងចំនួន ១៦ករណី ស្មើនឹង ៤៤%
  - រំលោភសេពសន្ថវៈ កើនឡើងចំនួន ១៣ករណី ស្មើនឹង ២២%
  - បង្ខាំងមនុស្សដំរិតយកប្រាក់ កើនឡើង ៦ករណី ស្មើនឹង ៦០០%
  - បង្ខាំងមនុស្សខុសច្បាប់ ថយចុះចំនួន ០២ករណី ស្មើនឹង ២៥%
- គិតត្រឹមខែឧសភា ឆ្នាំ២០២៤ លទ្ធផលបង្ក្រាបគ្រឿងញៀន សរុបចំនួន ១៨១២ករណី ឃាត់ខ្លួនបាន ចំនួន ៤៤៥១នាក់ (ស្រី ៣០៥នាក់) និងចាប់យកគ្រឿងញៀនសរុប ចំនួន ៣តោន ១២៦៤ក្រាម (វត្ថុតាង និងជនល្មើសទាំងអស់ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត)។

❖ **ស្ថិតិគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច**

- **គណបក្សនយោបាយ**
  - គិតត្រឹមខែមេសា ឆ្នាំ២០២៤ គណបក្សនយោបាយចុះបញ្ជីនៅក្រសួងមហាផ្ទៃ មានចំនួនសរុប **៤៧ គណបក្ស** ក្នុងនោះ គណបក្សនយោបាយចុះបញ្ជីមានចំនួន **៤៥** និងគណបក្សនយោបាយ បង្កើតថ្មីមានចំនួន **០២**។
- **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**
  - សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានចំនួនសរុប **៦,៣៤៦** រួមមាន៖ សមាគមចំនួន **២,៧៩៦** (ក្នុងនោះសមាគមសម្រាប់នីតិបុគ្គលចំនួន ៦៣)។
  - អង្គការមិនមែនរដ្ឋាភិបាលចំនួន **៣,៥៥០** (ក្នុងនោះ អង្គការសម្រាប់នីតិបុគ្គលចំនួន **០៥**)។
- **សហគមន៍ជនជាតិដើមភាគតិច**
  - សហគមន៍ជនជាតិដើមភាគតិចសរុបចំនួន **១៥៣**។
- **ការធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**

- ការធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចាប់ពីថ្ងៃទី២៥ ខែមីនា ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ បានទទួលលទ្ធផលសរុបចំនួន **៥.១៣២** ស្មើនឹង **៨២,៣៤%** (សមាគមចំនួន **២.២៦១** ស្មើនឹង **៨១,៦៥%** និងអង្គការចំនួន **២.៨៧១** ស្មើនឹង **៨២,៩០%**) រួមមានស្ថានភាពដូចខាងក្រោម៖

- ស្វែងរកឃើញចំនួន ១.៣០៤ ស្មើនឹង ២៥,៤0% នៃចំនួនដែលបានធ្វើជំរឿន ក្នុងនោះមាន សមាគមចំនួន ៦៤៦ និងអង្គការចំនួន ៦៥៨។
- ស្វែងរកឃើញមិនអាចផ្តល់សលាកបត្រព័ត៌មានចំនួន ៤២៣ និងអង្គការចំនួន ២៣១។
- ស្វែងរកមិនឃើញចំនួន ៣.៤០៥ ស្មើនឹង ៦៦,៣៤% នៃចំនួនដែលបានធ្វើជំរឿន ក្នុង នោះមាន សមាគមចំនួន ១.៩៨២។

## VII. សំណូមពរ

- ផ្តល់បទពិសោធការពារព្រឹត្តិការណ៍កម្រិតតំបន់ និងអន្តរជាតិ
- ស្នើភាគីកូរ៉េជួយបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា និងជំនាញប្រឆាំងការសម្អាតប្រាក់
- ស្នើផ្លាស់ប្តូរប្រតិភូ និងដកស្រង់បទពិសោធន៍ទៅវិញទៅមក
- បញ្ជូនគ្រូជំនាញមកបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងភេរវកម្ម រំដោះចំណាប់ខ្មាំង ជំនាញគ្រប់គ្រង សណ្តាប់ធ្នាប់សាធារណៈ បង្ការ ទប់ស្កាត់ សកម្មភាពបង្កចលាចលសង្គម និងបណ្តុះបណ្តាលគ្រូបង្គោល។

* * * * *

# ប្រវត្តិរូបសង្ខេប



## ឯកឧត្តម KIM Hyungwon

## ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌអន្តរជាតិ នៃក្រសួងយុត្តិធម៌

## I. បទពិសោធន៍ការងារ៖

- ឆ្នាំ២០២៤ - បច្ចុប្បន្ន ៖ ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌអន្តរជាតិ ក្រសួងយុត្តិធម៌
- ឆ្នាំ២០២៣ - ២០២៤៖ ប្រធាននាយកដ្ឋានឧក្រិដ្ឋកម្មសាធារណៈ និងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌអន្តរជាតិ នៃការិយាល័យរដ្ឋអាជ្ញាខេត្តប៊ូសាន
- ឆ្នាំ២០២១ - ២០២៣ ៖ មន្ត្រីផ្នែកស៊ើបអង្កេតឧក្រិដ្ឋកម្ម និងយុត្តិធម៌ព្រហ្មទណ្ឌ នៃការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកឧក្រិដ្ឋកម្ម និងគ្រឿងញៀន ទីក្រុងវីយែន
- ឆ្នាំ២០១៩ -២០២១ ៖ រដ្ឋអាជ្ញានៃការិយាល័យរដ្ឋអាជ្ញាខេត្ត Daejeon
- ឆ្នាំ២០១៧ -២០១៩ ៖ រដ្ឋអាជ្ញានៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌
- ឆ្នាំ២០១៤ ៖ ទីប្រឹក្សារបស់ធនាគារពិភពលោក
- ឆ្នាំ២០១២ - ២០១៤ ៖ រដ្ឋអាជ្ញានៃតំបន់ Wonju ប្រចាំការិយាល័យរដ្ឋអាជ្ញាខេត្ត Chuncheon
- ឆ្នាំ២០១០ - ២០១២ ៖ រដ្ឋអាជ្ញានៃការិយាល័យរដ្ឋអាជ្ញាទីក្រុង សេអ៊ូល
- ឆ្នាំ២០០៧ -២០១០ ៖ ចៅក្រមនៃក្រសួងការពារជាតិ

## II. ប្រវត្តិការសិក្សា

- ឆ្នាំ២០១៤ ៖ បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកច្បាប់ សាកលវិទ្យាល័យ Georgetown University Law Center
- ឆ្នាំ២០០៨ ៖ បរិញ្ញាបត្រជាន់ខ្ពស់ច្បាប់ផ្នែកសហគ្រាស សាកលវិទ្យាល័យជាតិ សេអ៊ូល
- ឆ្នាំ២០០៤ ៖ បរិញ្ញាបត្រសេដ្ឋកិច្ច សកលវិទ្យាល័យជាតិសេអ៊ូល

## III. វិជ្ជាជីវៈមេធាវី

- ទទួលបានសម្បទា នៅប្រទេសកូរ៉េ ក្នុងឆ្នាំ២០០៧
- ទទួលបានសម្បទា នៅរដ្ឋញូវយ៉ក សហរដ្ឋអាមេរិក ក្នុងឆ្នាំ២០១៥